# ការស្វែងយល់ពីចំណេះដឹង និងការចូលរួមសកម្មភាពផ្នែកនយោបាយ របស់យុវជន

## សេចក្តីផ្តើម

ការចូលរួមសកម្មភាពផ្នែកនយោបាយ សំដៅដល់សកម្មភាពនានាដែលជួយគាំទ្រ ឬជះឥទ្ធិពលដោយផ្ទាល់ ឬដោយប្រយោលទៅដល់គោលនយោបាយពាក់ព័ន្ធនឹងអភិបាលកិច្ច និងស្ថានភាពរស់នៅរបស់ប្រជាជន (Milbrath and Goel 1977)។ នៅក្នុងឯកសារសិក្សាពីនយោបាយ ការចូលរួមផ្នែកនយោបាយតែងផ្សារភ្ជាប់ទៅនឹងចំណេះដឹងផ្នែកនយោបាយ ឬក៏វិសាលភាពនៃព័ត៌មានពិតជាក់ស្តែងអំពី នយោបាយ និងរដ្ឋាភិបាល ដូចជាស្ថាប័ននយោបាយ និងអ្នកនយោបាយ ជាដើម។ ការស្រាវជ្រាវពីមុនបានរកឃើញថា ការចូលរួមក្នុងសកម្មភាពនយោបាយរបស់ប្រជាជន វាអាស្រ័យថា តើពួកគាត់មានចំណេះដឹងពីរឿងនយោបាយកម្រិតណា (Delli Carpini and Keeter 1996; Stithorn 2012)។ ការសិក្សាទាំងឡាយដែលផ្តោតជាពិសេសលើយុវជន តែងផ្សារភ្ជាប់បរិមាណនៃការចូលរួមផ្នែកនយោបាយរបស់គាត់ទៅនឹងកម្រិតនៃចំណេះដឹងផ្នែកនយោបាយ ពោលគឺអ្នកមានកម្រិតចំណេះដឹងផ្នែកនយោបាយតិច តែងមានការចូលរួមផ្នែកនយោបាយតិចទៅតាមនោះដែរ (Niemi and Junn 2005; Milner 2005)។

ប្រទេសកម្ពុជាមានចំនួនប្រជាជនវ័យក្មេងច្រើន ពោលគឺប្រជាពលរដ្ឋប្រមាណ ៦៥% មានអាយុក្រោម ៣០ឆ្នាំ (UNDP 2020) ហើយក្នុងនេះ ប្រមាណ ៣៣% (MoEYS 2011) មានអាយុពី ១៥-៣០ឆ្នាំ ដែលក្នុងរបាយការណ៍នេះហៅថា "យុវជន"។ យុវជនដើរតួនាទីសំខាន់ក្នុងផ្នែកនយោបាយ ហើយការអភិវឌ្ឍប្រទេសអាចសម្រេចទៅបាន លុះត្រាតែ ការចូលរួមសកម្មភាពនយោបាយរបស់យុវជន រួមជាមួយនឹងមនុស្សពេញវ័យ (អាយុលើស ៣០ឆ្នាំ) អាចហុចផលវិជ្ជមានដល់សង្គមជាតិ (Heng et al. 2014)។ យុវជនកម្ពុជាត្រូវបានគេមើលរំលងជាយូរមកហើយនៅក្នុងឆាកនយោបាយ ប៉ុន្តែ សន្ទុះនៃការចូលរួមសកម្មភាពនយោបាយរបស់គាត់ក្នុងទសវត្សរ៍ចុងក្រោយនេះ បានផ្លាស់ប្តូរបរិយាកាសនយោបាយនៅកម្ពុជា។ ដោយសារការប្រើប្រាស់អ៊ិនធើណិត និងបណ្តាញសង្គម មានភាពទូលំទូលាយច្រើនជាងមុន យុវជនក៏បានដឹងព័ត៌មាន និងមានបញ្ចេញសម្លេងច្រើន ហើយចូលរួមសកម្មភាពនយោបាយ កាន់តែច្រើនឡើងដែរ។ ក្នុងការបោះឆ្នោតឆ្នាំ២០១៣ មានការចូលរួមសកម្មភាពនយោបាយពីយុវជនយ៉ាងច្រើនមិនធ្លាប់ជួបពីមុន។ តាំងពីពេលនោះមក យុវជនក៏ក្លាយជាចំណុចស្នូលក្នុង គោលនយោបាយរបស់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល (NGOs) ជាច្រើន (OECD Development Center 2017)។

ការសិក្សានេះ មានគោលដៅធ្វើការប្រៀបធៀបចំណេះដឹងផ្នែកនយោបាយរបស់យុវជន ទៅនឹងមនុស្សពេញវ័យ ហើយបន្ទាប់មក សិក្សាពីទំនាក់ទំនងរវាង ចំណេះដឹង នឹងការចូលរួមផ្នែកនយោបាយរបស់យុវជន។ លទ្ធផលរកឃើញអាចជួយស្រាយបំភ្លឺពីរបៀបដែលយុវជនកម្ពុជា ចូលរួមក្នុងសកម្មភាពនយោបាយ និងពីកត្តានានាដែលជះឥទ្ធិពលទៅលើចំណេះដឹង និងសកម្មភាពទាំងនោះរបស់គាត់។ គេក៏អាចទាញយកជាមតិយោបល់ផ្នែកគោលនយោបាយ ដើម្បីព្យាយាមដោះស្រាយបញ្ហានានាដែលរារាំងការទទួលបានព័ត៌មាននយោបាយ និងការចូលរួមសកម្មផ្នែកនយោបាយរបស់យុវជនដែរ។

ក្នុងការសិក្សានេះ អ្នកស្រាវជ្រាវបានប្រើទិន្នន័យអង្កេតពីឆ្នាំ២០១៧ ដល់ ២០១៨ របស់វិទ្យាស្ថាន CDRI។ អង្កេតនេះប្រើសំណាកច្រើនស្រទាប់ នៃអ្នកឆ្លើយសម្ភាសន៍ ១.៦០០នាក់ ដែលជ្រើសយកតាមវិធីចៃដន្យ នៅក្រុងភ្នំពេញ និង ៥ខេត្ត (បាត់ដំបង កំពត ស្ទឹងត្រែង ស្វាយរៀង កំពង់ចាម)។ ក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍ មាន ៤០,២% ជាបុរស ៥៩,៨% ជាស្ត្រី ២៤,៩% ជាយុវជន ៧៥,១% ជាមនុស្សពេញវ័យ ២៦,៥% រស់នៅទីក្រុង និង ៧៥,៥% រស់នៅជនបទ។ បញ្ជីសំណួររួមមាន ១០១សំណួរពាក់ព័ន្ធនឹង លក្ខណៈប្រជាសាស្ត្ររបស់អ្នកឆ្លើយសម្ភាសន៍ អត្តសញ្ញាណនិងតម្លៃសីលធម៌ ទំនុកចិត្តនិងការគោរព ទស្សនវិស័យ ការចូលរួមសកម្មភាពនយោបាយ និង ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ (Eng et al. 2019)។

## ចំណេះដឹងផ្នែកនយោបាយរបស់យុវជនកម្ពុជា

ក្រុមស្រាវជ្រាវបានប្រើ ការវិភាគពីរអថេរ (bivariate analysis) លើទិន្នន័យអង្កេត ដើម្បីប្រៀបធៀបចំណេះដឹងផ្នែកនយោបាយរបស់យុវជន ជាមួយនឹងមនុស្សពេញវ័យ។ ការវិភាគបានពិនិត្យជាពិសេសលើ ភាពខុសគ្នានៃមធ្យម (mean difference) លើចំណេះដឹងនៃក្រុមអាយុទាំងពីរ ដោយប្រើ Two-Sample T-Test ។ ក្នុងអង្កេតនេះ គេមានសំណួរពីរទៅកាន់អ្នកឆ្លើយសម្ភាសន៍ ដើម្បីធ្វើតេស្តចំណេះដឹងរបស់គាត់ ស្តីពីអ្នកនយោបាយ (សូមប្រាប់ឈ្មោះអ្នកនយោបាយឲ្យបានយ៉ាងតិចបីនាក់ ក្រៅពីនាយករដ្ឋមន្ត្រី) និងចំណេះដឹងពីស្ថាប័ននយោបាយ (សូមប្រាប់ឈ្មោះស្ថាប័នកំពូលទាំងបីនៃរដ្ឋាភិបាល)។ សម្រាប់សំណួរនីមួយៗ គេឲ្យចម្លើយត្រូវ ២ពិន្ទុ ចម្លើយត្រូវខ្លះ ១ពិន្ទុ ចម្លើយខុស ពិន្ទុ០។ គេយកផលបូកនៃចម្លើយទាំងពីរ មកប្រើតំណាងឲ្យ ចំណេះដឹងផ្នែកនយោបាយរបស់អ្នកឆ្លើយសម្ភាសន៍។ លទ្ធផលនៃការវិភាគ ត្រូវបានសង្ខេបក្នុង តារាង១ (សូមមើលឧបសម្ព័ន្ធ១) និង រូបភាព១។

---

អត្ថបទនេះរៀបរៀងដោយ យ៉ង់ មុនីឧត្តម អ្នកប្រឹក្សាយោបល់, លាង សៀកឡេង អ្នកហាត់ការ និង សូ ហេងវត្តី ជំនួយការស្រាវជ្រាវ, នៃមជ្ឈមណ្ឌលពង្រឹងអភិបាលកិច្ច និងសង្គមសម្រាប់គ្រប់គ្នា នៃវិទ្យាស្ថាន CDRI។ សូមយោងអត្ថបទនេះថា៖ Yang Monyoudom, Leang Seakleng, and So Hengvotey. 2020. "Understanding Political Knowledge and Participation of Cambodian Youth." *Cambodia Development Review* 24 (1): 7–13។

រូបភាព១៖ ចំណេះដឹងផ្នែកនយោបាយរបស់យុវជន និងមនុស្សពេញវ័យ




កំណត់សំគាល់៖ ចំនួនសង្កេតឃើញ = 1,600

រូបភាព២៖ ភាពខុសគ្នាក្នុងការអប់រំ(ថ្នាក់រៀនចប់) រវាងយុវជន នឹងមនុស្សពេញវ័យ




កំណត់សំគាល់៖ ចំនួនសង្កេតឃើញ = 1,600

លទ្ធផលរកឃើញបង្ហាញថា យុវជននិងមនុស្សពេញវ័យ មានចំណេះដឹងទាក់ទងនឹងអ្នកនយោបាយប្រហាក់ប្រហែលគ្នា ប៉ុន្តែយុវជនហាក់ដឹងពីស្ថាប័ននយោបាយ ច្រើនជាងមនុស្សពេញវ័យ។ គិតជាមធ្យម យុវជនទំនងមានចំណេះដឹង ផ្នែកនយោបាយល្អជាងមនុស្សពេញវ័យ។ ថ្វីបើទិន្នន័យបង្ហាញថា យុវជនមានចំណេះដឹងល្អជាងមនុស្សពេញវ័យក្តី ប៉ុន្តែចំនួនយុវជនដែលឆ្លើយបានត្រឹមត្រូវ នៅមានភាគរយតិចនៅឡើយ។ ជាក់ស្តែងមានយុវជនត្រឹមតែ ៦៥% ប៉ុណ្ណោះ ដែលផ្តល់ចម្លើយបានត្រឹមត្រូវលើសំណួរ អំពីចំណេះដឹងផ្នែកនយោបាយ និង ២០% លើសំណួរអំពីចំណេះដឹងផ្នែកស្ថាប័ននយោបាយ។

ដើម្បីយល់ពីភាពខុសគ្នាខាងលើនេះ ក្រុមស្រាវជ្រាវបានធ្វើ regression អថេរចំណេះដឹងផ្នែកនយោបាយ ទៅលើអថេរមួយចំនួនទៀត ដូចជា អាយុ (Delli Carpini and Keeter 1996) យេនឌ័រ (Mondak and Anderson 2004) ទីតាំង (Pereira 2011) ប្រាក់ចំណូល (Lind 2011) ការអប់រំ (Delli Carpini and Keeter 1996; Niemi and Junn 2005) និង ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ (Pasek et al. 2006)។ ការសិក្សានេះបានកំណត់អថេរ ដូចជា (១) អាយុពី ១៦ ដល់ ៣០ (២) យេនឌ័រមានតម្លៃ ១ សម្រាប់ស្ត្រី និង ០ សម្រាប់បុរស (៣) ទីតាំងមានលេខកូដ ១ សម្រាប់ទីក្រុង និង ០ សម្រាប់ជនបទ (៤) ប្រាក់ចំណូលចាប់ពី ០ ដល់ ១.២០០ម៉ឺនរៀល (៥) ការអប់រំមានតម្លៃ ០ សម្រាប់បឋមសិក្សា ឬទាបជាង, ១ សម្រាប់មធ្យមសិក្សា, ២ សម្រាប់សាកលវិទ្យាល័យ (៦) ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ គឺជាចំនួនម៉ោងសរុបដែលបុគ្គលម្នាក់ៗចំណាយអានសារព័ត៌មានបោះពុម្ព មើលទូរទស្សន៍ និង ប្រើអ៊ីនធើណិតក្នុងមួយថ្ងៃ។ ក្រុមស្រាវជ្រាវបានប្រើ Ordinary Least Squares (OLS) ដើម្បីធ្វើ regression ហើយលទ្ធផលត្រូវបានបង្ហាញក្នុងតារាង២ (សូមមើល ឧបសម្ព័ន្ធ២)។

រូបភាព៣៖ ភាពខុសគ្នាក្នុងការប្រើប្រព័ន្ធផ្សព្វផ្សាយ រវាងយុវជន នឹងមនុស្សពេញវ័យ




កំណត់សំគាល់៖ ចំនួនសង្កេតឃើញ = 1,600

ស្រដៀងគ្នានឹងការសិក្សានានាដូចលើកខាងលើដែរ លទ្ធផលរកឃើញបានបង្ហាញថា ការអប់រំ និងការប្រើប្រព័ន្ធផ្សព្វផ្សាយមានឥទ្ធិពលវិជ្ជមានលើចំណេះដឹងផ្នែកនយោបាយ។ លទ្ធផលនេះអាចបញ្ជាក់បានថា យុវជនមានចំណេះដឹងផ្នែកនយោបាយប្រសើរជាងមនុស្សពេញវ័យ ដោយសារយុវជនមានទំនោរទទួលបានការអប់រំខ្ពស់ (រូបភាព២) និងប្រើប្រព័ន្ធផ្សព្វផ្សាយច្រើនជាងមនុស្សពេញវ័យ (រូបភាព៣)[១]។ ការអប់រំជាមធ្យោបាយមួយដើម្បី ជំរុញមនុស្ស បណ្តុះឲ្យមានចំណូលចិត្ត និងបង្កើនលទ្ធភាពរៀនសូត្រពីនយោបាយ (Delli Carpini and Keeter 1996)។ ម្យ៉ាងទៀត យុវជន និងមនុស្សពេញវ័យរាយការណ៍ថា ប្រព័ន្ធផ្សព្វផ្សាយជាប្រភពព័ត៌មាននយោបាយសំខាន់បំផុតរបស់ខ្លួនក្រៅពីក្រុមមនុស្សជិតស្និទ្ធ អាជ្ញាធរ និងអង្គការផ្សេងៗ ហើយអ៊ីនធើណិត ហាក់ដូចមានប្រជាប្រិយភាពខ្លាំង សម្រាប់ក្រុមយុវជន (រូបភាព៤)។ ហេតុនេះហើយ ការចំណាយពេលច្រើនក្នុងការប្រើប្រព័ន្ធផ្សព្វផ្សាយ តែងជួយបង្កើនឱកាសស្វែងរក និងស្គាល់ដឹងពីព័ត៌មានផ្នែកនយោបាយផ្សេងៗ ពោលគឺ ចំណេះដឹងផ្នែកនយោបាយ។

១ របបប្រល័យពូជសាសន៍ ប៉ុល ពត និងសង្គ្រាមស៊ីវិល បានបង្អាក់ការអប់រំនៅកម្ពុជា (IIEP-UNESCO 2011)។ ស្របគ្នានឹងការរីកចម្រើនបច្ចេកវិទ្យា និងប្រព័ន្ធផ្សព្វផ្សាយ គេអាចយល់បានថា យុវជនដែលជាមនុស្សជំនាន់ថ្មី តែងមានការអប់រំ និងការប្រើប្រព័ន្ធផ្សព្វផ្សាយ បានល្អជាង។

រូបភាព៤៖ ប្រភពព័ត៌មានផ្នែកនយោបាយសម្រាប់យុវជន និងមនុស្សពេញវ័យ




កំណត់សំគាល់៖ ចំនួនសង្កេតឃើញ = 1,600, CBOs=អង្គការផ្អែកលើសហគមន៍

រូបភាព៥៖ ទស្សនៈរបស់យុវជនពីសារៈសំខាន់នៃការមានគំនិតយោបល់ឯករាជ្យផ្នែកនយោបាយ




កំណត់សំគាល់៖ ចំនួនសង្កេតឃើញ = 398

រូបភាព៦៖ អារម្មណ៍របស់យុវជនពីសេរីភាពផ្នែកនយោបាយនៅក្នុង និងនៅក្រៅអ៊ិនធើណិត




កំណត់សំគាល់៖ ចំនួនសង្កេតឃើញ = 398

យុវជនឆ្លើយសម្ភាសន៍ជាច្រើននាក់ បានប្រាប់ពីអារម្មណ៍ថា មានកង្វះខាតខ្លះនូវសេរីភាពផ្នែកនយោបាយនៅក្នុង និងក្រៅប្រព័ន្ធអ៊ិនធើណិត ដែលអាចរារាំងដល់ការទទួលបានចំណេះដឹងផ្នែកនយោបាយ។ ថ្វីបើមានយុវជន ៩៣% បានឆ្លើយថា ការអាចមានគំនិតយល់ឃើញផ្នែកនយោបាយផ្ទាល់ខ្លួន វាជាការសំខាន់ ប៉ុន្តែមានយុវជនដល់ទៅ ២១% ដែលភ័យខ្លាចក្នុងការស្វែងរកព័ត៌មានផ្នែកនយោបាយក្នុងអ៊ិនធើណិត ៣៤% ភ័យខ្លាចក្នុងការចែករំលែកព័ត៌មាននយោបាយតាមអ៊ិនធើណិត និង ៥៤% ភ័យខ្លាច ក្នុងការពិភាក្សាផ្តល់គំនិតយោបល់ផ្នែកនយោបាយក្រៅអ៊ិនធើណិត (រូបភាព៥)។

យ៉ាងណាមិញ ប្រព័ន្ធនយោបាយនៅកម្ពុជា នៅមានការរឹតត្បិតនៅឡើយ។ ជាឧទាហរណ៍ ការពិភាក្សា និងការជួបប្រជុំផ្នែកនយោបាយ ត្រូវបានហាមឃាត់នៅតាមសាលារៀន (Yong 2005)។ គេក៏ឃើញមានកំណត់ត្រាការគៀបសង្កត់ និងការបង្ក្រាបខ្លាំងក្លាលើការតវ៉ា ក៏ដូចជាការធ្វើបាតុកម្មដោយសន្តិវិធី (Henke 2011; Department of State 2012; COMFREL 2013; LICADHO 2014)។ ហើយថ្វីបើការប្រើអ៊ិនធើណិតយ៉ាងទូលំទូលាយនាបច្ចុប្បន្ន បានធ្វើឲ្យបណ្តាញសង្គមក្លាយជាឧបករណ៍ដ៏មានប្រសិទ្ធភាព ក្នុងការផ្តល់ព័ត៌មានថ្មីទាន់ពេល ការពិភាក្សា និងការប្រមូលមតិគ្នាក្តី ប៉ុន្តែជារឿយៗអ្នកប្រើប្រាស់តែងទទួលនូវ ការគំរាមកំហែងតាមផ្លូវច្បាប់ជាបណ្តឹងអះអាងថាគាត់បានបំពានសេរីភាពក្នុងការបញ្ចេញមតិរបស់ខ្លួន (Sok 2015; Sun 2019)។ បញ្ហាទាំងអស់នេះបានបំផុស និងបន្តការភ័យខ្លាចក្នុងចំណោមយុវជន ធ្វើឲ្យគាត់នៅឃ្លាតឆ្ងាយពីនយោបាយ (Heng et al. 2014)។

## ការចូលរួមសកម្មភាពផ្នែកនយោបាយរបស់យុវជនកម្ពុជា

នៅកម្ពុជា យុវជនចូលរួមយ៉ាងសកម្ម ក្នុងការបោះឆ្នោតថ្នាក់ជាតិ ប៉ុន្តែពួកគាត់មានការចូលរួមតិចតួចប៉ុណ្ណោះ ក្នុងអភិបាលកិច្ចកម្រិតមូលដ្ឋាន ជាពិសេសក្នុងដំណើរការកសាងផែនការអភិវឌ្ឍឃុំ[២]។ យុវជនអ្នកឆ្លើយសម្ភាសន៍ ៩៩% បានទទួលស្គាល់ថា គាត់មើលឃើញការចូលរួមបោះឆ្នោតជាកាតព្វកិច្ច ពោលគឺ គាត់ត្រូវតែទៅបោះឆ្នោត (រូបភាព៧)។ ក្នុងចំណោមយុវជនមានសិទ្ធិបោះឆ្នោត ៤៩% បានទៅបោះឆ្នោតថ្នាក់ជាតិឆ្នាំ២០១៣ ៧១% បានទៅបោះឆ្នោតថ្នាក់ឃុំឆ្នាំ២០១៧ និងមានរហូតដល់ ៩៣% គ្រោងនឹងទៅបោះឆ្នោតថ្នាក់ជាតិដ៏ចម្រូងចម្រាស់នៅឆ្នាំ២០១៨ (ដែលពេលនោះ គណបក្សប្រឆាំងត្រូវបានគេហាមឃាត់) (រូបភាព៨)។ សម្រាប់ការចូលរួមក្នុងអភិបាលកិច្ចនៅកម្រិតមូលដ្ឋាន មានយុវជន ៣៧% បានចូលរួម

---

២ សម្រាប់ព័ត៌មានបន្ថែមស្តីពី ដំណើរការកសាងផែនការអភិវឌ្ឍន៍ នៅកម្រិតឃុំ សូមអាន "Decentralization" by CDC-CRDB and "Guideline on C/S Development Plan and C/S Investment Program" by Inter-ministerial Working Group.

រូបភាព៧៖ យុវជនមានអារម្មណ៍ថា ខ្លួនមានកាតព្វកិច្ចទៅបោះឆ្នោត




កំណត់សំគាល់៖ ចំនួនសង្កេតឃើញ = 398

រូបភាព៨៖ យុវជនបានទៅបោះឆ្នោត (អាយុមានសិទ្ធិបោះឆ្នោត៖ ១៨ឆ្នាំ)




កំណត់សំគាល់៖ ចំនួនយុវជនមានសិទ្ធិបោះឆ្នោត = 352 ក្នុងចំណោម 398

រូបភាព៩៖ ការចូលរួមរបស់យុវជនក្នុងអភិបាលកិច្ចកម្រិតមូលដ្ឋាន




កំណត់សំគាល់៖ ចំនួនសង្កេតឃើញ = 398

រូបភាព១០៖ ការប្រជុំពិគ្រោះយោបល់នៅថ្នាក់ភូមិ និងឃុំ




កំណត់សំគាល់៖ ចំនួនសង្កេតឃើញ = 398

ក្នុងការប្រជុំថ្នាក់ភូមិ ១៩% ក្នុងការប្រជុំថ្នាក់ឃុំ ១៣% ក្នុងការឃ្លាំមើលការអនុវត្តគម្រោងថ្នាក់ឃុំ និង ១០% ក្នុងវេទិកាសាធារណៈ (រូបភាព១០)។ រូបភាព១១ បង្ហាញថា ការចូលរួមរបស់យុវជន ក្នុងសកម្មភាពនយោបាយជាទូទៅ មិនបានញឹកញាប់នោះទេ ដោយមានយុវជនតែ ៧% ប៉ុណ្ណោះ ដែលរាយការណ៍ថា គាត់បានចូលរួមក្នុងសកម្មភាពផ្នែកនយោបាយកាលពីខែមុន។

ក្រុមស្រាវជ្រាវបានប្រើ ម៉ូដែល multivariate regression មួយចំនួនទាក់ទងទៅនឹង ការបោះឆ្នោតរបស់យុវជន ក៏ដូចជាការចូលរួមក្នុងអភិបាលកិច្ចនៅកម្រិតមូលដ្ឋានរបស់គាត់ ដើម្បីពន្យល់ពីទំនាក់ទំនងជាទូទៅរវាង ចំណេះដឹង និងការចូលរួមផ្នែកនយោបាយរបស់យុវជន។ ក្នុងម៉ូដែលទាំងនេះ គ្រប់លំនាំនៃការបោះឆ្នោតរបស់យុវជន និងការចូលរួមរបស់គាត់នៅថ្នាក់ភូមិនិងឃុំ ត្រូវបានគេចាត់ទុកជា អថេរពឹងផ្អែក (dependent

រូបភាព១១៖ ការចូលរួមរបស់យុវជននៅខែមុន




កំណត់សំគាល់៖ ចំនួនសង្កេតឃើញ = 398

variables) ហើយអថេរនីមួយៗត្រូវបានគេលើកយកមកសិក្សាដាច់ដោយឡែកពីគ្នា។ អថេរពឹងផ្អែកទាំងអស់ ត្រូវបានគេវាស់វែងស្របតាមចម្លើយរបស់យុវជន ទៅនឹងសំណួរស្ទង់មតិដែលជាប់ទាក់ទងគ្នានោះ ពោលគឺមាន តម្លៃ ១ សម្រាប់ការបានចូលរួម និង 0 សម្រាប់ការមិនបានចូលរួម។ នៅក្នុងម៉ូដែលទាំងនេះ ក៏មានចំណេះដឹងផ្នែកនយោបាយជាអថេរឯករាជ្យ (independent variable) ចម្បង ហើយចំពោះអថេរដទៃទៀតដូចជា អាយុ យេនឌ័រ ទីតាំង ប្រាក់ចំណូល ការអប់រំ និង ការប្រើប្រព័ន្ធផ្សព្វផ្សាយ គឺត្រូវបានគេត្រួតពិនិត្យ ព្រោះឯកសារស្រាវជ្រាវពីមុនៗ បានបញ្ជាក់ថា អថេរទាំងនេះ អាចជះឥទ្ធិពលខ្លះទៅលើការចូលរួមផ្នែកនយោបាយរបស់បុគ្គលនីមួយៗ (Stithorn 2012; Adegbola and Gearhart 2019)។ ដោយហេតុថា អថេរពឹងផ្អែកទាំងអស់ សុទ្ធសឹងជា អថេរគោលពីរ (binary variables) ដូច្នេះក្រុមស្រាវជ្រាវបានប្រើវិធី logistic regression ដើម្បីអាចសិក្សាម៉ូដែលទាំងអស់បាន ដូចមានចុះក្នុង តារាង៣ (សូមមើលឧបសម្ព័ន្ធ៣)។

លទ្ធផលបង្ហាញថា ចំណេះដឹងផ្នែកនយោបាយ មានមេគុណវិជ្ជមាន (positive coefficients) ដែលអាចយកជាការបានសម្រាប់គ្រប់លំនាំនៃ ការចូលរួមសកម្មភាពផ្នែកនយោបាយទាំងអស់ លើកលែងតែការបោះឆ្នោតនៅថ្នាក់ជាតិ និងការឃ្លាំមើលការអនុវត្តគម្រោងថ្នាក់ឃុំ។ ចំណុចនេះមានន័យថា យុវជនដែលមានចំណេះដឹងផ្នែកនយោបាយច្រើន រមែងតែងចូលរួមច្រើនដែរក្នុងការបោះឆ្នោតថ្នាក់ឃុំ និង ការប្រជុំពិគ្រោះយោបល់នៅថ្នាក់ភូមិ និងឃុំ លើកលែងតែ ការឃ្លាំមើលការអនុវត្តគម្រោងថ្នាក់ឃុំ។ និយាយដោយខ្លី ការមានចំណេះដឹងច្រើនផ្នែកនយោបាយ នាំឲ្យមានការចូលរួមផ្នែកនយោបាយច្រើនដូចគ្នា។ ប៉ុន្តែបើនិយាយពីទំនាក់ទំនង ជាហេតុនិងផល រវាងចំណេះដឹងនឹងការចូលរួមផ្នែកនយោបាយតែម្តង គឺវាពុំមានភាពច្បាស់លាស់នោះទេ ព្រោះទំនាក់ទំនងនេះអាចមានទាំងពីរទិស (ទៅ-មក)។ ជាក់ស្តែង ចំណេះដឹងផ្នែកនយោបាយច្រើន អាចលើកទឹកចិត្តយុវជន ឲ្យចូលរួមសកម្មភាពផ្នែកនយោបាយច្រើន ប៉ុន្តែយុវជនក៏អាចទទួលបានចំណេះដឹងកាន់តែច្រើនដែរ តាមរយៈការចូលរួមសកម្មភាពផ្នែកនយោបាយជាច្រើនរបស់គាត់។ ទោះបីជាវាពិបាក ក្នុងការកំណត់ទិសដៅនៃទំនាក់ទំនង ជាហេតុនិងផល រវាងចំណេះដឹង នឹងការចូលរួមសកម្មភាពផ្នែកនយោបាយរបស់យុវជនឲ្យបានច្បាស់លាស់ក្តី យុវជនទាំងឡាយគប្បីត្រូវមានចំណេះដឹងជាមូលដ្ឋានផ្នែកនយោបាយ ដើម្បីអាចចូលរួមជាប្រយោជន៍ដល់សង្គមនយោបាយនៅកម្ពុជា (Milner 2002)។

## សេចក្តីសន្និដ្ឋាន

តាមការធ្វើវិភាគដោយប្រើ ពីរអថេរ និង ច្រើនអថេរ នេះ ក្រុមស្រាវជ្រាវបានរកឃើញថា យុវជនកម្ពុជាតែងដឹងព័ត៌មានផ្នែកនយោបាយ បានប្រសើរជាងមនុស្សជំនាន់មុន។ ចំណេះដឹងច្រើនជាងផ្នែកនយោបាយនេះ វាជាប់ទាក់ទងនឹងការអប់រំខ្ពស់ជាង និងការប្រើប្រព័ន្ធផ្សព្វផ្សាយច្រើនជាងរបស់យុវជន ដែលជួយឲ្យពួកគាត់អាចទទួលបាន ព័ត៌មានជាក់ស្តែងផ្នែកនយោបាយផ្សេងៗយ៉ាងច្រើន។ លទ្ធផលបែបនេះ ជាសញ្ញាលើកទឹកចិត្តមួយដល់ការអភិវឌ្ឍផ្នែកនយោបាយនៅកម្ពុជា ព្រោះយុវជន គឺជាក្រុមនយោបាយចម្បងមួយ ហើយពួកគាត់មានការចាប់អារម្មណ៍ទៅលើនយោបាយ និងមិនចូលរួមសកម្មភាពនយោបាយនានាទាំងងងឹតងងល់ ដូចលទ្ធផលរកឃើញបានបង្ហាញថា នៅពេលយុវជនមានចំណេះដឹងផ្នែកនយោបាយកាន់តែច្រើន ពួកគាត់តែងចូលរួមនៅក្នុងសកម្មភាពនយោបាយកាន់តែច្រើនដូចគ្នា។ ទោះជាយ៉ាងណាក៏ដោយ នៅមានយុវជនជាច្រើននាក់ដែរដែលនៅខ្វះចំណេះដឹងផ្នែកនយោបាយ ហើយគួបផ្សំនឹងអារម្មណ៍ថាខ្វះសិទ្ធិសេរីភាពផ្នែកនយោបាយទៀតផងនោះ ការចូលរួមផ្នែកនយោបាយរបស់ពួកគាត់ នឹងមានកកម្រិត។ ហេតុនេះហើយ រដ្ឋាភិបាលកម្ពុជា និងអង្គការសង្គមស៊ីវិលជាប់ពាក់ព័ន្ធទាំងឡាយ គួររួមសហការគ្នា កសាងបរិយាកាសនយោបាយអំណោយផលមួយ ដែលយុវជនអាចទទួលអារម្មណ៍ថា ខ្លួនមានសិទ្ធិអំណាច មិនមែនភ័យខ្លាចក្នុងការស្វែងរកព័ត៌មានផ្នែកនយោបាយ និងចូលរួមជាប្រយោជន៍នៅក្នុងសកម្មភាពនយោបាយនោះទេ។

ការស្រាវជ្រាវនេះ នៅមានកង្វះខាតខ្លះដែលការសិក្សានាពេលអនាគតគួរជួយដោះស្រាយ។ ចំណេះដឹងផ្នែកនយោបាយជាគោលគំនិតមួយយ៉ាងធំទូលាយ ដែលក្តោបរាល់ព័ត៌មានជាក់ស្តែងផ្នែកនយោបាយផ្សេងៗ ប៉ុន្តែសូចនាករនៃចំណេះដឹងផ្នែកនយោបាយ ដែលត្រូវបានយកមកប្រើក្នុងការវិភាគនេះ ផ្អែកលើតែ ២សំណួរ ស្តីពី ចំណេះដឹងផ្នែកនយោបាយប៉ុណ្ណោះ ដែលអាចធ្វើឲ្យកត្តាតាង (proxy) មិនអាចវាស់វែងបានត្រឹមត្រូវនូវចំណេះដឹងផ្នែកនយោបាយជាទូទៅរបស់យុវជន។ ទិន្នន័យអង្កេតទៀតសោត ក៏ស្រង់បានតាំងពីចុងឆ្នាំ២០១៧ ដល់ដើមឆ្នាំ២០១៨ មកម្ល៉េះ។ ដោយហេតុថា តាំងពីពេលនោះមក ស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច ក៏ដូចជាសង្គមនយោបាយ និងប្រព័ន្ធផ្សព្វផ្សាយ វាបានផ្លាស់ប្តូរជាបន្តបន្ទាប់ ដែលអាចធ្វើឲ្យប្រែប្រួលដល់ឥរិយាបថ និងសកម្មភាពផ្នែកនយោបាយរបស់យុវជននៅឆ្នាំ២០២០ នេះ។

## ឯកសារយោង


Adegbola, Oluseyi and Sherice Gearhart. 2019. *International Journal of Communication* 13(2019): 1231-1251.

CDC-CDRD. 2002. “Decentralization.” http://www.cdc-crdb.gov.kh/cdc/ngo_statement/decentralization.htm, accessed 26 Mar 2020.

COMFREL. 2013. *Democracy, Elections, and Reform in Cambodia*. 2012 Annual Report. Phnom Penh: COMFREL.

Delli Carpini, M. and S. Keeter. 1996. *What Americans Know about Politics and Why It Matters*. New Haven, CT: Yale University Press.

Department of State. 2012. *Cambodia 2012 Human Rights Report*. Country Report. Washington DC: Department of State.

Eng Netra, Ang Len, So Hengvotey, Hav Gechhong and Chhom Theavy. 2019. *Cambodia's Young and Older Generation: Views on Generational Relations and Key Social and Political Issues*. Working Paper Series No. 116. Phnom Penh: CDRI.

Heng Seiha, Vong Mun and Chheat Sreang. 2014. *The Enduring Gap: Decentralization Reform and Youth Participation in Local Rural Governance*. Working Paper Series No. 94. Phnom Penh: CDRI.

Henke, Roger. 2011. "NGOs, People's Movements and Natural Resource Management." In *Cambodia's Economic Transformation,* edited by Caroline Hughes and Kheang Un, 288-309. Copenhagen: NIAS Press.

IIEP-UNESCO. 2011. *Education and Fragility in Cambodia*. IIEP Research Paper. Paris: IIEP-UNESCO.

Inter-ministerial Working Group. 2007. *Guideline on C/S Development Plan and C/S Investment Program*. Phnom Penh: Inter-ministerial Working Group.

LICADHO. 2014. *Human Rights 2013: The Year in Review*. Human Rights Report. Phnom Penh: LICADHO.

Lind, Jo Thori and Dominic Rohner. 2011. *Knowledge is Power: A Theory of Information, Income, and Welfare Spending*. Working Paper Series No. 36. Zürich: Department of Economics at University of Zürich.

Milbrath, Lester W. and Manda La Goel. 1977. *Political Participation: How and Why People Get Involved in Politics*. Chicago: Rand McNally.

Milner, Henry. 2002. "Civic Literacy: How Informed Citizens Make Democracy Work." *Canadian Journal of Political Science* 36 (3): 676-679.

Milner, Henry. 2005. "Are Young Canadians Becoming Political Dropouts? A Comparative Perspective." *IRPP Choices* 11 (3): 1-26.

MoEYS. 2011. *National Policy on Youth Development*. Phnom Penh: MoEYS.

Mondak, J. and M. Anderson. 2004. "The Knowledge Gap: A Reexamination of Gender based Differences in Political Knowledge." *Journal of Politics* 66: 492-512.

Niemi, Richard and Jane Junn. 2005. *Civic Education: What Makes Students Learn*. New Haven: Yale University Press.

OECD Development Center. 2017. *Youth Well-being Policy Review of Cambodia*. Report for the EU-OECD Youth Inclusion Project Country Review. Paris: OECD Development Center.

Pasek, Josh, Romer Dan and Kate Kenski. 2006. "America's Youth and Community Engagement: How Use of Mass Media Is Related to Civic Activity and Political Awareness in 14- to 22-Year-Olds." *Community Research* 33 (3): 115-135.

Pereira, Federico Batista. 2011. *Politcal Knowledge Levels across the Urban-Rural Divide in Latin America and the Caribbean*. Latin American Public Opinion Project, AmericasBarometer Insights Series No. 68. Nashville: Vanderbilt University.

Sok Khemara. 2015. "Media Experts Warn against a Cyber-crime Law that Hurts Online Freedom." *VOA Cambodia*. 12 Oct 2015. https://www.voacambodia.com/a/media-experts-warn-against-a-cyber-crime-law-that-hurts-online-freedom/3002439.html.

Stithorn Thananithichot. 2012. "Political Engagement and Participation of Thai Citizens: The Rural-Urban Disparity." *Contemporary Politics* 18 (1): 87-108.

Sun Narin. 2019. "Cambodia Takes Aim Critics Who Post on Facebook." *VOA Cambodia*. 16 Mar 2019. https://www.voanews.com/east-asia-pacific/cambodia-takes-aim-critics-who-post-facebook.

UNDP. 2020. "About Cambodia." https://www.kh.undp.org/content/cambodia/en/home/countryinfo.html#Introduction, accessed 27 Apr 2020.

Yong Kim Eng. 2005. *Force of the Future? Youth Participation in Politics in Cambodia*. Country Paper in Go! Young Progressives in Southeast Asia. Manila: Beate Martin, FES Philippines Office.

## ឧបសម្ព័ន្ធ

### *ឧបសម្ព័ន្ធ ១*

តារាង១៖ ភាពខុសគ្នាក្នុងចំណេះដឹងពីនយោបាយ រវាងយុវជន នឹងមនុស្សពេញវ័យ

| អថេរ | យុវជន | មនុស្សពេញវ័យ | តួលេខខុសគ្នា |
|---|---|---|---|
| ចំណេះដឹងនយោបាយ | | | |
| អ្នកនយោបាយ | 1.49 | 1.5241 | 0.0342 |
| | (0.0381) | (0.0214) | (0.0437) |
| ស្ថាប័ន | 0.5151 | 0.3353 | 0.1798*** |
| | (0.0404) | (0.0196) | (0.0448) |
| សរុប | 2.005 | 1.8594 | 0.1456** |
| | (0.0623) | (0.0328) | (0.0705) |

កំណត់សំគាល់៖ ចំនួនសង្កេតឃើញ = 1,600
Standard errors are reported in brackets.
* * * denotes P-value < 0.01, * * denotes P-value < 0.05.

## ឧបសម្ព័ន្ធ ២

តារាង២៖ លទ្ធផលការធ្វើ OLS regression លើកត្តាប៉ះពាល់ដល់ចំណេះដឹងផ្នែកនយោបាយ

| អថេរ | មេគុណ (coefficient) |
|---|---|
| អាយុ | 0.0038** |
| | (0.0019) |
| ភេទឪរ/ស្ត្រី | -0.4898*** |
| | (0.0552) |
| ទីតាំង/ទីក្រុង | 0.1154* |
| | (0.0614) |
| ប្រាក់ចំណូល | 0.0106 |
| | (0.0124) |
| ការអប់រំ | 0.6888*** |
| | (0.0502) |
| ការប្រើប្រព័ន្ធផ្សព្វផ្សាយ | 0.0487*** |
| | (0.01) |

កំណត់សំគាល់៖ ចំនួនសង្កេតឃើញ = 1,594
សង្កេតមានបាត់ខ្លះដោយសារព័ត៌មានទទួលបានមិនពេញលេញ
Robust standard errors ចុះក្នុងវង្វង់ក្រចក
* * * denotes P-value < 0.01, * * denotes P-value < 0.05, * denotes P-value <0.1.

## ឧបសម្ព័ន្ធ ៣

តារាង៣៖ លទ្ធផលនៃ Logistic regression លើទំនាក់ទំនងរវាងចំណេះដឹង នឹងការចូលរួមផ្នែកនយោបាយរបស់យុវជន

| អថេរ | ការបោះឆ្នោតក្នុងពេលបោះឆ្នោត | | | ការចូលរួមនៅថ្នាក់ភូមិ និងឃុំ | | | |
|---|---|---|---|---|---|---|---|
| | ថ្នាក់ជាតិ ឆ្នាំ២០១៣ | ថ្នាក់ឃុំ ឆ្នាំ២០១៧ | ថ្នាក់ជាតិ ឆ្នាំ២០១៨ (រំពឹងទុក) | ការប្រជុំ ថ្នាក់ភូមិ | ការប្រជុំ ថ្នាក់ឃុំ | ការឃ្លាំមើល ការអនុវត្ត គម្រោងថ្នាក់ឃុំ | វេទិកា សាធារណៈ |
| ចំណេះដឹង ផ្នែកនយោបាយ | 0.2052 | 0.2087** | 0.1917 | 0.2913*** | 0.2792** | 0.0155 | 0.2896* |
| | (0.1555) | (0.1065) | (0.148) | (0.107) | (0.116) | (0.1351) | (0.1801) |
| អាយុ | 0.485*** | 0.2633*** | 0.2464*** | 0.1456*** | 0.0926*** | 0.0388 | 0.1154** |
| | (0.0457) | (0.0327) | (0.0495) | (0.0285) | (0.0328) | (0.0411) | (0.0487) |
| ភេទឪរ/ស្ត្រី | 0.4054 | 0.3297 | -0.0398 | -0.1138 | -0.0143 | -0.2931 | -0.0431 |
| | (0.3158) | (0.2616) | (0.3493) | (0.2416) | (0.2786) | (0.3073) | (0.3403) |
| ទីតាំង/ទីក្រុង | 0.3933 | 0.0358 | -0.0357 | -0.6127* | -0.1156 | -0.1293 | -0.3662 |
| | (0.4171) | (0.3286) | (0.4716) | (0.321) | (0.3734) | (0.4544) | (0.4731) |
| ប្រាក់ចំណូល | 0.1058* | 0.1012* | 0.0949 | -0.1039* | 0.048 | 0.0341 | 0.0087 |
| | (0.0662) | (0.0586) | (0.0673) | (0.0572) | (0.0706) | (0.0728) | (0.0867) |
| ការអប់រំ | 0.5178* | 0.6667*** | 0.0658 | -0.7142*** | -0.3942* | -0.166 | -0.1438 |
| | (0.275) | (0.232) | (0.3318) | (0.2206) | (0.2675) | (0.3203) | (0.3372) |
| ការប្រើប្រព័ន្ធ ផ្សព្វផ្សាយ | -0.01 | -0.0015 | 0.0796 | 0.0044 | -0.0063 | -0.0456 | 0.0596 |
| | (0.0537) | (0.0455) | (0.071) | (0.0398) | (0.0467) | (0.0586) | (0.057) |
| N | 398 | 398 | 398 | 398 | 398 | 398 | 398 |
| Pseudo R-squared | 0.4386 | 0.2434 | 0.1809 | 0.1116 | 0.0474 | 0.0167 | 0.0477 |
| Wald Chi-square | 129.82 | 98.38 | 31.09 | 49.87 | 19.83 | 6.08 | 9.8 |
| P-value | 0.0000 | 0.0000 | 0.0001 | 0.0000 | 0.0059 | 0.5308 | 0.1999 |

កំណត់សំគាល់៖ N គឺជាចំនួនសង្កេតឃើញ
Robust standard errors are reported in brackets.
* * * denotes P-value < 0.01, * * denotes P-value < 0.05, * denotes P-value < 0.1.